**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២១៨ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋទំហំ ១៩១៥,៧០ ហិកតា ស្ថិតក្នុងសង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង សម្រាប់ធ្វើសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់និតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនិតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់និតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
-បានឃើញសេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាលេខ ៤២ សជណ.ថក ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៩ ស្តីពីគោលនយោបាយផ្តល់សម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ
-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.~**

ត្រូវបានកាត់ចេញពីផែនទីគម្របព្រៃឈើឆ្នាំ ២០០២ ទីតាំងដី ១ កន្លែងមានទំហំ ១៩១៥,៧០ (មួយពាន់ប្រាំបួនរយដប់ប្រាំក្បៀសចិតសិប) ហិកតា នៅក្នុងសង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ដូចមានបង្ហាញក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ដោយកំណត់តាមចំណុចគោលដែលមាននិយាមកានៃប្រព័ន្ធកូអរដោនេ UTM_ Zone 48 N, Datum: WGS 1984 ដូចខាងក្រោម៖

| ចំណុច | X | Y | ចំណុច | X | Y | ចំណុច | X | Y |
|---|---|---|---|---|---|---|---|---|
| 0 | 617441 | 1514103 | 11 | 613607 | 1505850 | 22 | 616130 | 1507235 |
| 1 | 613878 | 1512343 | 12 | 612781 | 1503836 | 23 | 616200 | 1507883 |
| 2 | 614209 | 1511621 | 13 | 612128 | 1503329 | 24 | 616595 | 1509026 |
| 3 | 614577 | 1510999 | 14 | 613075 | 1502258 | 25 | 616673 | 1509505 |
| 4 | 614625 | 1510764 | 15 | 613415 | 1501925 | 26 | 617202 | 1510337 |
| 5 | 614559 | 1510325 | 16 | 613951 | 1502320 | 27 | 617279 | 1510789 |
| 6 | 614637 | 1509556 | 17 | 615100 | 1502778 | 28 | 617752 | 1511402 |
| 7 | 614153 | 1507920 | 18 | 615199 | 1503427 | 29 | 617949 | 1511825 |
| 8 | 614484 | 1507861 | 19 | 615820 | 1505444 | 30 | 618034 | 1512587 |
| 9 | 614069 | 1506860 | 20 | 616299 | 1505881 | | | |
| 10 | 613360 | 1506021 | 21 | 616384 | 1506572 | | | |

**មាត្រា ២.~**

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ ១៩១៥,៧០ (មួយពាន់ប្រាំបួនរយដប់ប្រាំក្បៀសចិតសិប) ហិកតា ដូចមានចែងក្នុងមាត្រា ១ ខាងលើនៃអនុក្រឹត្យនេះ ដែលជាដីសាធារណៈរបស់រដ្ឋ មកជាដីឯកជនរបស់រដ្ឋ។

ត្រា ៣.~

ត្រូវបានប្រគល់អណាត្តិកាន់កាប់ដីឯកជនរបស់រដ្ឋដូចមានក្នុងមាត្រា ២ ខាងលើនេះ ជូនអភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែងជាអាជ្ញាធរកាន់កាប់ដីរដ្ឋ ដើម្បីស្នើសុំចុះបញ្ជីជាដីឯកជនរបស់រដ្ឋ និងសម្រាប់ធ្វើសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ។

ត្រា ៤.~

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

ត្រា ៥.~

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១១

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
ងព្រះបរមរាជវាំង
បខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
បខាធិការដ្ឋានព្រឹទ្ធសភា
បខាធិការដ្ឋានរដ្ឋសភា
បខាធិការដ្ឋានរាជរដ្ឋាភិបាល
លើយសម្តេចនាយករដ្ឋមន្ត្រី
បមាជិក គសសជ
លខាធិការដ្ឋាន គសសជ
ត្រា ៥
ទូ
ារ-កាលប្បវត្តិ

ផែនទីបង្ហាញទីតាំងសម្បទានដីសង្គមកិច្ច ទំហំ ១៩១៥.៧០ (មួយពាន់ប្រាំបួនរយដប់ប្រាំក្បៀសចិតសិប) ហិកតា
ស្ថិតនៅក្នុងសង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង

ឧបសម្ព័ន្ធអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១១




| ID | X | Y |
|---|---|---|
| 0 | 617441 | 1514103 |
| 1 | 613878 | 1512343 |
| 2 | 614209 | 1511621 |
| 3 | 614577 | 1510999 |
| 4 | 614625 | 1510764 |
| 5 | 614559 | 1510325 |
| 6 | 614637 | 1509556 |
| 7 | 614153 | 1507920 |
| 8 | 614484 | 1507861 |
| 9 | 614069 | 1506860 |
| 10 | 613360 | 1506021 |
| 11 | 613607 | 1505850 |
| 12 | 612781 | 1503836 |
| 13 | 612128 | 1503329 |
| 14 | 613075 | 1502258 |
| 15 | 613415 | 1501925 |
| 16 | 613951 | 1502320 |
| 17 | 615100 | 1502778 |
| 18 | 615199 | 1503427 |
| 19 | 615820 | 1505444 |
| 20 | 616299 | 1505881 |
| 21 | 616384 | 1506572 |
| 22 | 616130 | 1507235 |
| 23 | 616200 | 1507883 |
| 24 | 616595 | 1509026 |
| 25 | 616673 | 1509505 |
| 26 | 617202 | 1510337 |
| 27 | 617279 | 1510789 |
| 28 | 617752 | 1511402 |
| 29 | 617949 | 1511825 |
| 30 | [illegible] | 1512587 |